**Declassified to Public**
**06 September 2012**



ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception):
26-Jun-2009, 14:11
ម៉ោង (Time/Heure):
Chanthan Phok

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification):
26-Jun-2009
Chanthan Phok

ម្តាយខ្ញុំដែរ ។ គាត់ជាអ្នកកាន់សិល សាសនាយេស៊ូ ដែលស្អប់ខ្ពើមណាស់អ្នកណាដែល គ្មានជំនឿទៅលើព្រះ ។ គាត់តែងតែនិយាយប្រាប់កូនៗថា បើកុម្មុយនីសទឹកដាល់ វានឹងបង្កបង្កើតគ្រោះថ្នាក់យ៉ាងខ្លាំងដល់អ្នកកាន់សាសនាយេស៊ូ ។ ឪពុកខ្ញុំក៏បានផ្តល់ ការគាំទ្រខាងផ្នែកនយោបាយមកខ្ញុំដែរ គឺថាបុគ្គលម្នាក់ពុំមានត្រូវការចែកចាយលុយ-

កាក់ដែលរកបានពីញើឈាមខ្លួនជាមួយនរណាទៀតក្រៅពីគ្រួសារខ្លួនផ្ទាល់ទេ ។ បើជនណាខិតខំធ្វើការខ្លាំង ជននោះត្រូវតែទទួលរង្វាន់តាមការខំប្រឹងប្រែងរបស់ខ្លួន ។ បើសិនជាមានរបបកុម្មុយនីស្តមកនៅក្នុងប្រទេសអូស្ត្រាលី វាមុខជានិងអស់-មានជីវិតរស់នៅតាមរបៀបគ្រួសារម្នាក់ៗដែលខ្ញុំធ្លាប់ស្គាល់ទៀតហើយ ។

ខ្ញុំមានឪពុកមារម្នាក់ឈ្មោះ ជេម អាកស៊ើន ស្កុត James Arthur SCOTT ជាលក្តិ ៣ នៅក្នុងកងទ័ពអូស្ត្រាលី ។ គាត់ឈប់ធ្វើទាហានហើយ ប៉ុន្តែគាត់នៅតែបន្តធ្វើការឱ្យសេអ៊ីអា ។ គាត់បានបង្ហាត់អប់រំកងទ័ពហើយនិងភ្នាក់ងារសេអ៊ីអាចូលថ្មី អំពីចារកម្មយោធា ជាក់ស្តែងនៅពេលសង្គ្រាមលោកលើកទី ២ ។ គាត់ក៏បាននិយាយប្រាប់ខ្ញុំដែរថា ចាំបាច់ត្រូវតែមានក្រសួងចារកម្មអន្តរជាតិមួយធំ មាន-ប្រសិទ្ធិភាព ' ដើម្បីទប់ទល់និងកុម្មុយនីស ' ។

ឆ្នាំ ១៩៥៨ ខ្ញុំចាប់ផ្តើមរៀនបញ្ចប់មធ្យមសិក្សានៅវិទ្យាល័យវិស្លី Wesley College ក្នុងសង្កាត់ខាងត្បូងនៃទីក្រុងពែល ។ វិទ្យាល័យនេះជាសាលាកាន់កាប់ដោយពួក-លោកសង្ឃសាសនា យេស៊ូ ម៉េសូឌីស Methodist Church ។ ការអប់រំខាងផ្នែកសាសនានៅសាលានេះ វាដូចគ្នានិងការអប់រំដើមដែលខ្ញុំធ្លាប់បានទទួលពីម្តាយខ្ញុំ-ហើយរិតតែពង្រឹងការស្អប់ខ្ពើមរបស់ខ្ញុំចំពោះកុម្មុយនីសថែមទៀត ។

កាលខ្ញុំរៀននៅវិទ្យាល័យវិស្លី ពេលថ្ងៃអាទិត្យខ្ញុំច្រើនតែចេញមកលេងផ្ទះពូខ្ញុំឈ្មោះ ជេម ។ នៅទីនោះ ខ្ញុំបានជួបស្គាល់និងមិត្តភក្តិគាត់មួយចំនួន ហើយក៏បានចូលស្តាប់ការពិភាក្សាផ្សេងៗ និយាយអំពីសេអ៊ីអា អំពីចលនាសហជីព ហើយនិងការងារចារកម្ម ។ ហើយនៅកន្លែងនោះដដែល ខ្ញុំបានជួបស្គាល់និងជនម្នាក់ឈ្មោះ រ៉ឺកាកទែរ Ray CARTER ដែលធ្លាប់នៅក្នុងកងទ័ពហើយជាមន្ត្រីសេអ៊ីអា ។ គាត់ជាអ្នក

Extracted from ERN: 00007904-00008067

ទើបភ្នាក់ងារធ្វើឱ្យសេអ៊ីអានៅក្នុងរដ្ឋវិសទើន អូស្ត្រាលីយ៉ា ។ នាត់នេះហើយជាអ្នកស្នើឱ្យខ្ញុំរៀនបន្តនៅវិទ្យាល័យកសិកម្មមូរ៉ិស Mureck Agricultural College អាណារៀនចប់នៅវិទ្យាល័យនិស្ស ។ ខែមករា ឆ្នាំ ១៩៦៣ ខ្ញុំក៏ចូលរៀននៅមូរ៉ិស ។

វិទ្យាល័យមូរ៉ិស ជាវិទ្យាល័យកន្លែងក្លាយរបស់សេអ៊ីអានៅប្រទេសអូស្ត្រាលីដែល-ប្រើវាសំរាប់អប់រំភ្នាក់ងារនិស្សិត ។ និស្សិតដែលចេញពីការអប់រំអស់ ២ ឆ្នាំនៅវិទ្យាល័យនេះអាចចូលទៅរៀននៅឆ្នាំទី ២ នៃសកលវិទ្យាល័យ ឬទៅរៀននៅវិជ្ជាជ្ជានឧត្តមសិក្សាផ្សេងៗទៀត ឬមួយចេញទៅធ្វើការតែម្ដង ។ និស្សិតទាំងអស់-សុទ្ធតែបានទទួលការអប់រំផ្សេងៗដើម្បីធ្វើភ្នាក់ងារសេអ៊ីអា ។ វិទ្យាល័យមូរ៉ិសស្ថិត-ចម្ងាយ ១៦ ម៉ាយ "២៦គ.ម" ពីខាងទិសនិរតីនៃទីប្រជុំជនន័រថាំ Northam ហើយពីចម្ងាយ ៦២ ម៉ាយ "១០០គ.ម" ពីខាងកើតនៃទីក្រុងពែស នៅក្នុងរដ្ឋវិសទើន អូស្ត្រាលីយ៉ា ។ វាចាប់ស្ថាបនានៅឆ្នាំ ១៩៤៦ ហើយពីដើមជាកន្លែងមួយផ្នែកនៃបន្ទាយអប់រំរបស់កងទ័ពនៅន័រថាំ ។ មួយឆ្នាំៗវិទ្យាល័យមូរ៉ិសទទួលនិស្សិត ៥០នាក់ៗ

នៅឆ្នាំទី ១ មានមុខវិជ្ជាសំរាប់ចូលរៀននៅសកលវិទ្យាល័យ ហើយនិងវិជ្ជាកសិកម្មជាទូទៅ ។ មានការអប់រំផ្សេងៗខាងផ្នែកប្រវត្តិសាស្ត្រសម័យដោយយោងទៅតាមគោលគមវិជ្ជាសេអ៊ីអា ហើយនិងការបង្រៀនឱ្យស្គាល់យល់ដឹង ហើយនិងជ្រួត-ជ្រាបអំពីនយោបាយរបស់សេអ៊ីអាដែរ ។ រាល់អាទិត្យទី ២ តែងតែមានការអនុវត្តជាក់ស្ដែង បង្រៀនឱ្យចេះឈានមុខ ចេះរស់នៅក្នុងសភាពការណ៍លំបាក ចេះថែរក្សាកម្លាំងកាយឱ្យល្អ ហើយនិងហាត់កីឡាផ្សេងៗ ព្រមទាំងចេះបើកបររថយន្ត-ហើយនិងស្គាល់គ្រឿងក្រៅម៉ាស៊ីនផ្សេងៗ ។ និស្សិតណាមួយក៏ត្រូវរៀនមុខវិជ្ជាទូទៅ

នេះដែរ ។ ម្យ៉ាងទៀតក៏មានការជំរុញឱ្យបណ្ដុះលូតលាស់ទេពកោសល្យម្នាក់ៗផង ជាពិសេសនៅក្នុងផ្នែកកីឡា ។ វិទ្យាល័យអូរីលមានសំភារៈគ្រប់គ្រាន់ទាំងអស់សំរាប់បំពេញលក្ខភាពផ្សេងៗ ។

ឆ្នាំទី ២ ជាឆ្នាំដែលត្រូវជ្រើសរើសយកទេសតាមមុខងាររបររកសុីដែលនិស្សិតម្នាក់ៗ ។ ហើយព្រមជាមួយគ្នានេះដែរ មានមុខវិជ្ជាទូទៅនិយាយអំពីនយោបាយសេអ៊ីអា នយោបាយអន្តរជាតិ ហើយនិងការទាក់ទងគ្នាតាមផ្លូវទូត ព្រមទាំងកិច្ចការប្រចាំថ្ងៃ ។ គ្រូបង្រៀនជាមន្ត្រីសេអ៊ីអាដែលរស់នៅក្នុងសាលាជាប្រចាំ ។ ខាងផ្នែកការងារអនុវត្តជាក់ស្ដែងធ្វើជាភ្នាក់ងារសេអ៊ីអា ការអប់រំវិជ្ជាធ្វើជាលង្វាក់លឿន ហើយនិស្សិតម្នាក់ៗអាចជ្រើសរើសយកទេសក្នុងផ្នែក ឧស្សាហកម្ម នយោបាយ ពាណិជ្ជកម្ម វិទ្យាសាស្ត្រ ឬទូទៅ ។

នៅឆ្នាំទី ២ ខ្ញុំជ្រើសរើសមុខវិជ្ជាជាទូទៅ ហើយនិងការស៊ើបតាមដានជាក់-ស្ដែង ។ ខាងផ្នែកស៊ើបតាមដាន ត្រូវរៀនខាងទ្រឹស្ដីអស់ ១០ ថ្ងៃពីបញ្ហានិមួយៗ ហើយទើបធ្វើការអនុវត្តជាក់ស្ដែងអស់ ៥ ថ្ងៃ ។ នៅក្នុងនេះមានការរៀនថតរូប ប្រើប្រាស់គ្រឿងអល្លាំង ទាក់ទងគ្នាតាមវិទ្យុ ស៊ើបការហើយនិងគូរផែនទី ហើយនិងរៀនបើកឡានយ៉ាងលឿន ។ ត្រូវចេះផ្លែងលាក់មុខងារពិតប្រាកដផង នៅពេលដែលត្រូវធ្វើការស៊ើបតាមដាន ។ មន្ត្រីសេអ៊ីអា ៦ នាក់រស់នៅជាប្រចាំ - ក្នុងវិទ្យាល័យ គឺលោក ២ ប៉ាត់ ស្លូន Pat Sloan កិនហ៊ិច Ken Hicks លោក ៣ (ដន សាត់ហ្វ៉ត់) (Don Shadforth)
ពីទើរ ហ្គាកស្ដោន Peter Garstone ប៉ាត់ កុន្ន័រ Pat Connors
ហើយនិងលោក ៥ តូនី ហ្វីឡាន Tony Phelan ។ ទាំង ៦ នាក់ជាគ្រូ - បង្រៀន ចំណែកការងារផ្ទះ ហើយនិងកសិដ្ឋានគឺជាភារកិច្ចបុគ្គលិកទាហានចាស់នៅក្នុង

Extracted from ERN: 00007904-00008067

00007921





កងទ័ពអូស្ត្រាលី ។

ខ្ញុំប្រឡងជាប់នៅខែមិនា ឆ្នាំ ១៩៦៥ ហើយពាក់ស័ក្តិជានាយទោ សេអ៊ីអា លេខ ១១៥៦២ ។ ខ្ញុំត្រូវទទួលប្រាក់ខែ ១៨២០ ដុល្លារក្នុងមួយឆ្នាំៗ ហើយនិងសញ្ញាប័ត្រមួយខាងផ្នែកវិទ្យាសាស្ត្រកសិកម្ម ។

ខ្ញុំទៅរស់នៅជាមួយនិងឪពុកម្តាយខ្ញុំ ហើយត្រូវរាយការណ៍ពីសកម្មភាពនៃនិស្សិតជឿនលឿនទៅ តូនី ហ៊ីទ្យ៉ាន់ ។ ខែកញ្ញា ឆ្នាំ ១៩៦៧ ខ្ញុំចូលធ្វើការនៅក្រ-សួងពិសោធគ្រឿងញៀនអូស្ត្រាលីក្នុងទីក្រុងពែល ហើយចាប់ផ្តើមរាយការណ៍ពីសកម្មភាពសហជីពដែលទាក់ទងជាមួយនិងមុខងាររបស់ខ្ញុំ ។ "ខ្ញុំចូលទៅក្នុងផែនការស្រេចចិត្ត-ដើម្បីជ្រើសរើសយកគ្រឿងញៀនមកធ្វើពិសោធន៍" ។ សេអ៊ីអា ស្នើឱ្យខ្ញុំទៅរៀនមុខវិជ្ជាបញ្ចូលបង្កប់ខ្លួននៅក្នុងសហជីពនៅសាលាបច្ចេកទេសនៃទីក្រុងហ្វ្រីម៉ាន់ទិល Fremantle ដែលមានស័ក្តិ ៤ សេអ៊ីអា ឈ្មោះ ជុន ក្លិន John Glenn ធ្វើជាគ្រូបង្រៀន ។ ខ្ញុំចាប់ផ្តើមរៀននៅខែកុម្ភៈ ឆ្នាំ ១៩៦៨ ប៉ុន្តែនៅខែមិនា ខ្ញុំត្រូវរបួសនៅឆ្អឹងខ្នង ជាហេតុដែលនាំឱ្យខ្ញុំធ្វើអ្វីមិនកើតរហូតដល់ខែមិថុនា ប៉ុន្តែខ្ញុំ-នៅតែបន្តរៀនផ្ទាល់ខ្លួនដោយយកសៀវភៅមកអានមើលនៅផ្ទះ ។ ក្រោយមកខ្ញុំអាចធ្វើការស្រាលៗបាន ។ ខ្ញុំចាប់ផ្តើមបំពេញមុខងារជាអ្នករៀបចំទស្សនកិច្ច ឱ្យក្រុមភ្លេងមួយឈ្មោះ ធី បេកឃឺរី The Bakery ។ ខ្ញុំត្រូវរៀបចំសំភារៈចាត់ចែងទីស្នាក់អាស្រ័យហើយនិងដឹកជញ្ជូនផ្សេងៗ កាលណាត្រូវទៅលេងភ្លេងនៅទីណាមួយ ។

ខ្ញុំពត៌មានប្រាប់ទៅ តូនី ហ៊ីទ្យ៉ាន់ នៅប៉ូលិសថា ខ្ញុំអាចធ្វើសកម្មភាពឱ្យសេអ៊ីអា-បានឡើងវិញសាជាថ្មី ។ គាត់ក៏ធ្វើឧទ្ទេសនាមណែនាំឱ្យខ្ញុំស្គាល់ស័ក្តិ ៣ សេអ៊ីអា-ឈ្មោះ ជុនហុបគីន John Hopkins ដែលធ្លាប់បានឃើញៗនៅសាលាបច្ចេកទេសនៃ

Extracted from ERN: 00007904-00008067

ទីក្រុងប្រ៊ីនម៉ានចិលរួចមកហើយ ។ ជុន ហុបគីន ត្រូវធ្វើជាមន្ត្រីនាយបញ្ជាការផ្ទាល់របស់ខ្ញុំ ហើយគាត់ជាអ្នកចាត់ចែងភារកិច្ចផ្សេងៗឲ្យខ្ញុំ នៅទីណាដែលពួកខ្ញុំត្រូវទៅលេងភ្លេង ។ នៅពាក់កណ្ដាលឆ្នាំ ១៩៦៩ ពួកយើងខ្ញុំត្រូវធ្វើទស្សនកិច្ចនៅជុំវិញប្រទេសអូស្ត្រាលី ហើយ ជុន ហុបគីន ក៏រៀបចំបេសកកម្មឲ្យខ្ញុំបំពេញនៅទីក្រុងផ្សេងៗ ។ ដោយសារតែមុខងារពិតប្រាកដខ្ញុំធ្វើជាអ្នកចាត់ចែងភ្លេងយ៉ាងនេះ ខ្ញុំអាចចូលទៅស៊ើបការនៅក្នុងចំណោមពួកនិស្សិត ឬពួកអ្នកដើរលេងបានយ៉ាងងាយស្រួល ។ រួចហើយខ្ញុំក៏ធ្វើសេចក្ដីរាយការណ៍ឲ្យទៅ ជុន ហុបគីន ជាបន្តបន្ទាប់ ។ នៅដើមឆ្នាំ ១៩៧១ ពួកនិស្សិតនៅប្រទេសអូស្ត្រាលីទាំងមូលបានរៀបចំជាមីទិញមួយធំ-នៅទីក្រុងកាន់បេរ៉ា Canberra ហើយខ្ញុំក៏បានថតបញ្ចូលសម្លេងការប្រជុំពិភាក្សាគ្នាជាច្រើន ដើម្បីបញ្ជូនវាទៅឲ្យ ជុន ហុបគីន ស្ដាប់ ។ ចំពោះភារកិច្ចនេះ ខ្ញុំបានទទួលលុយកាក់ពីសេអ៊ីអាច្រើនថែមទៀត គឺទទួលជាប្រាក់ខែ ២៥០០ ដុល្លាក្នុងមួយឆ្នាំ ។ រួចហើយ ជុន ហុបគីន បានចាត់តាំងឲ្យខ្ញុំទៅបន្តរៀនសូត្រពីសក្ដិ ២ -សេអ៊ីអាម្នាក់ឈ្មោះ ជុន សីយើរ John Sayer នៅទីក្រុងម៉ិលប៊ួន Melbourne ។ ជុន សីយើរជាវិស្វករម្នាក់ខាងជំនាញខាងផ្នែកថតសម្លេងគាត់ធ្វើការឲ្យសេអ៊ីអា ជាអ្នករៀបចំគ្រឿងក្រោលបន្លាប់សម្លេងផ្សេងៗ ។ ខ្ញុំរៀនបច្ចេកទេសរៀបចំ-ដាក់ឌីក្រូហើយនិងប្រដាប់ថតសម្លេងតូចល្អិត ហើយនិងថតសម្លេងពិភាក្សាគ្នាឲ្យបានច្បាស់ល្អបំផុត ។ ខ្ញុំរៀនសូត្រជាមួយ សីយើរ រហូតដល់ខែវិច្ឆិកាឆ្នាំ ១៩៧១ នៅពេលនោះខ្ញុំបែកចេញពីក្រុមភ្លេងហ្វ្រីបេកឺវី ហើយត្រឡប់ទៅលេងវិស្សមកាលនៅរដ្ឋវិលថែន អូស្ត្រាលីយ៉ា ។ ខែកុម្ភៈ ឆ្នាំ ១៩៧២ ខ្ញុំធ្វើដំណើរទៅទីក្រុងស៊ីតនី -ហើយខ្ញុំធ្វើការនៅទីនោះជាអ្នកចាត់ចែងទស្សនកិច្ចឲ្យសិល្បករផ្សេងៗ ។ ការិយាល័យ

Extracted from ERN: 00007904-00008067

ខ្ញុំនៅក្នុងអាគារមួយដែលស្ថិតនៅក្នុងផ្លូវហ្គូលប៊ើនស្ទ្រីតនៃទីក្រុងស៊ីដនី Goulburn Street Sydney ហើយដែលមានជនម្នាក់ឈ្មោះ រ៉ីអាណុល Ray Arnold ជាអ្នកទទួលខុសត្រូវ ។ គាត់នេះជាសក្ដិ ២ សេអ៊ីអា ហើយរូបខ្លួនធ្វើជាអ្នកចាត់ចែងទស្សនកិច្ចនេះ ។

នៅក្នុងឆ្នាំ ១៩៧២ ខ្ញុំហើយ ជុន លីវើរ ឈ្មោះត្រៀមកាលប្រជុំមុខងារ - ដែលងាយរបស់ខ្ញុំដើម្បីរៀបចំដាក់ប្រឆាំងស្ថាប័នសន្តិសុខនៅក្នុងផ្ទះនៃកុងស៊ុលប្រទេសលីបង់ប្រចាំទីក្រុងម៉ិលបួន ។ ពួកយើងបង់បានភស្តុតាងច្បាស់លាស់ពីសកម្មភាពនយោបាយខុស - ច្បាប់នៃក្នុងកុងស៊ុលដែលកំពុងតែបែកសាមគ្គីនៅក្នុងចំណោមជនជាតិលីបង់ដែលរស់នៅក្នុងប្រទេសអូស្ត្រាលី ហើយនិងនាំលុយគេចេញទៅក្រៅប្រទេស ។ កាលណាយកការបានហើយ សេអ៊ីអានិងបញ្ជូនពត៌មាននោះទៅឱ្យរដ្ឋការអូស្ត្រាលី ។

ខែឧសភា ឆ្នាំ ១៩៧២ ជុន ហុបគីន និយាយប្រាប់មកខ្ញុំថា រ៉ីអាណុល ត្រូវធ្វើជាមន្ត្រីមេបញ្ជាការរបស់ខ្ញុំ ហើយខ្ញុំត្រូវរាយការណ៍អ្វីៗប្រាប់ទៅគាត់ ។ រួចហើយ - ទើប រ៉ី អាណុល ចាត់ចែងការងារថ្មីមកឱ្យខ្ញុំ ហើយខ្ញុំត្រូវរាយការណ៍តាមមាត់ផ្ទាល់ប្រាប់ទៅគាត់ ។ ខ្ញុំត្រូវឃ្លាំមើលក្រុមសិស្សអន្តរជាតិវៀតណាមដែលមកបំពេញទស្សនកិច្ចនៅប្រទេសអូស្ត្រាលី ពីព្រោះនៅក្នុងចំណោមពួកនោះ មានបុគ្គលខ្លះដែលមានសកម្មភាពប៉ះពាល់ដល់សន្តិសុខនៃប្រទេសជាតិអាមេរិក ។

ខែឧសភា ឆ្នាំ ១៩៧២ ខ្ញុំបានទាក់ទងមិត្តភាពនិងបុរសពីរនាក់ឈ្មោះ រ៉ូណាល់ឌីន - Ronald Dean ហើយនិង គីមបាកណាប៊ី Kim Barnaby ។ យើងមានមិត្តភក្តិដូចពុកម៉ា ហើយនិងចូលចិត្តដើរលេងស៊ីផឹកជាមួយគ្នាផង ។ រ៉ូណាល់ឌីនធ្វើការនៅភោជនីយដ្ឋានមួយ ឯគីមបាកណាប៊ី ជាអ្នកស៊ីឈ្នួលមុជទឹកនៅក្នុងសមុទ្រ ។ ខែ[illegible]

ឆ្នាំ ១៩៧៣ ខ្ញុំបានជួបស្គាល់និងនារីម្នាក់ឈ្មោះ ផាយ៉ាន់ ស្កាន្ទិល ដែលខ្ញុំត្រូវរៀបការជាមួយនៅថ្ងៃក្រោយ ។

ខ្ញុំបន្តធ្វើការស៊ើបអង្កេតឱ្យសេអ៊ីអាយ៉ាងនេះ រហូតនៅខែមិថុនា ឆ្នាំ១៩៧៣ សេអ៊ីអាករណុលធ្វើឱ្យខ្ញុំលួចនាមដែលនាំប្រាប់ខ្ញុំទៅជនជាតិអាមេរិកម្នាក់ឈ្មោះ ការ៉ុល [illegible] ជាសក្តិ ៤ សេអ៊ីអា ។ ការ៉ុលស្នើឱ្យខ្ញុំទៅរៀនបច្ចេកទេសចំតរូប ៣ ថ្ងៃនៅកន្លែងមួយហៅថា កសិដ្ឋាន ។ កន្លែងនោះជាទីហាត់ហ្វឹកហ្វឺនមួយយ៉ាងទំនើបសំ - រាប់ភ្នាក់ងារសេអ៊ីអា ហើយតាំងនៅក្នុងតំបន់ព្រៃភ្នំនៃរដ្ឋវឺជីញ៉ា ទៅ វើល ចម្ងាយប្រវែលបើកឡានអស់ ៤ ម៉ោងពីទីក្រុងស៊ីតនី ។ សក្តិ ៤ ការ៉ុល ជាមន្ត្រីសេអ៊ីអា ជាន់ខ្ពស់បំផុតដែលខ្ញុំត្រូវបានជួប ។ ក្រោយពីធ្វើសាកល្បងសិក្សាចប់ហើយនិងបានសិក្សាភាសាពីបុគ្គលខ្លះដែលខ្ញុំត្រូវតាមដាន ការ៉ុលបានបញ្ជាក់ឱ្យខ្ញុំទៅឡើងសក្តិជាពលបាល [illegible] ។ ហើយខ្ញុំត្រូវទទួលជាប្រាក់ខែនិងសោហ៊ុយផ្សេងៗទៀតលុយ ៣៧៥០ - ដុល្លាក្នុងមួយឆ្នាំ ។ ខ្ញុំទទួលជាលេខផ្សេងលេខ CA ៣៧៦ ។ ខ្ញុំប្រាប់គាត់ថាខ្ញុំចង់រៀបការជាមួយ ផាយ៉ាន់ ហើយនិងត្រឡប់ទៅរស់នៅឯវត្តរិមចែខ ស្ប្រូណាលី - វិញ ។

ខ្ញុំបន្តការងារស៊ើបអង្កេតឱ្យសេអ៊ីអាដែលទៀត ហើយមានពេល ២ ដង ខ្ញុំបានធ្វើការជាមួយភ្នាក់ងារសេអ៊ីអាមួយក្រុមដែលស្នាក់នៅកន្លែងប្រជុំធំមួយពីព្រោះនៅក្នុងចំណោមនោះ មានបុគ្គលមួយចំនួនដែលសេអ៊ីអាកំពុងតាមដានមើលសកម្មភាព ។ ខែមករា ឆ្នាំ ១៩៧៤ ខ្ញុំបានជួបនិង ការ៉ុល សាជាថ្មី ។ គាត់ស្នើឱ្យខ្ញុំរៀបចំជីវិតថ្មីរបស់ខ្ញុំ មុននិងគិតដល់បញ្ហាមុខវិជ្ជាអ្វីៗទៀតជាមួយនិងសេអ៊ីអា ។ ខ្ញុំត្រូវធ្វើជាភ្នាក់ងារជំនួយសិនបានហើយ ។ ខ្ញុំរៀបចំអាពាហ៍ពិពាហ៍ជាមួយ ផាយ៉ាន់ នៅខែមករា

ឆ្នាំ ១៩៧៤ ហើយក៏ត្រូវត្រឡប់មករស់នៅឯរដ្ឋវីរ៉ុលវែន អូស្ត្រាលីវិញនៅខែកុម្ភៈ ។

ខែមិនា ឆ្នាំ ១៩៧៤ ខ្ញុំរកបានការធ្វើជាអ្នកជួយកាន់កាប់ទទួលខុសត្រូវកសិដ្ឋានរបស់ - ជនម្នាក់ឈ្មោះ ជុន គូក John Cook នៅក្រូលីន Kwolyin ។ ដាយ៉ាន់ ហើយនិងខ្ញុំក៏បន្តរស់នៅធ្វើការនៅទីនោះទៅ ។

ខែកញ្ញា ឆ្នាំ ១៩៧៥ ខ្ញុំទទួលពត៌មានថា នៅស្រុកខ្ញុំរស់នៅមានមន្ត្រីប៉ូលីសហើយ - និងអ្នកធ្វើនយោបាយខ្លះដែលចូលរួមជាមួយពួកចោរប្រព្រឹត្តបទឧក្រិដ្ឋ មានវៃឯវៃល្បែង ស៊ីសង ហើយនិងការពារស្រីពេស្យាផងដែរ ។ ខ្ញុំក៏រាយការណ៍ប្រាប់ទៅ ការ៉ុល តាមរយៈខ៊ន រ៉ីភាកណុល ដែលបានមកជួបនិងខ្ញុំនៅទីក្រុងពែល ។ សេអ៊ីអាក៏ស៊ើប តាមដានរឿងនេះ ហើយបញ្ជូនពត៌មានជាបន្តទៅរដ្ឋាភិបាលអូស្ត្រាលី ។ ខ៊ុ អាកណុល បញ្ជាក់ប្រាប់មកខ្ញុំថា ខ្ញុំត្រូវធ្វើសេចក្តីរាយការណ៍ទៅសក្តិ ២ សេអ៊ីអាម្នាក់ដែលរស់នៅ ក្នុងរដ្ឋវីរ៉ុលវែន អូស្ត្រាលីហ្នា ហើយដែលតែងតែមកជួបទាក់ទងនិងខ្ញុំ ។ ប៉ុន្តែខ្ញុំនៅ ដែលបន្តធ្វើជាភ្នាក់ងារជំនួយដដែល ។ ខែធ្នូ ឆ្នាំ ១៩៧៥ សក្តិ ២ សេអ៊ីអាឈ្មោះ - គ្រីស រីឆាតសុន Chris Richardson មកជួបនិងខ្ញុំ ហើយគាត់បញ្ជាក់ប្រាប់ ខ្ញុំថា គាត់នេះហើយជាមន្ត្រីមេបញ្ជាការរបស់ខ្ញុំ ។

ខែមេសា ឆ្នាំ ១៩៧៧ ដាយ៉ាន់ ហើយនិងខ្ញុំបានលាលែងគ្នា ។ ដាយ៉ាន់ ត្រឡប់ទៅរស់នៅជាមួយម្តាយគាត់ឯស៊ីតនីវិញ ចំណែកខ្ញុំ ខ្ញុំត្រូវបើកហាងលក់វិទ្យុ ទាក់ទងគ្នាឱ្យកសិករដែលនៅឆ្ងាយដាច់ស្រយាល ហើយត្រូវត្រឡប់មកធ្វើការជាភ្នាក់ងារ សេអ៊ីអាពេញលក្ខណៈវិញ ។ នៅក្នុងរយៈកាលពីខែមិថុនា ទៅខែវិច្ឆិកា ឆ្នាំ ១៩៧៧ ខ្ញុំមិនធ្លាប់បានបំពេញសកម្មភាពអ្វីច្រើនឱ្យសេអ៊ីអាទេ ។ មានតែបេសកកម្មមួយ ធំដែលខ្ញុំបានដើរតួជាសំខាន់ដើម្បីចាប់ជនពីរនាក់ក្នុងចំណោមជន ៥ នាក់ ដែលបាន -

Extracted from ERN: 00007904-00008067

ប្រកាសថានិងដាក់គ្រាប់បែកកំទិចស្ថានីយ៍គមនាគមន៍នៅនាស់ វិសកេប North West Cape ។ កងទ័ពអាមេរិកប្រើស្ថានីយ៍គមនាគមន៍នេះដើម្បីទាក់ទងជាមួយ ជើងទឹក កងនាវាមុជទឹករហូតដល់មហាសមុទ្រអាត្លង់ទិកខាងត្បូង ។ សកម្មភាពទីទ្វេរនា-នេះជាការតវ៉ាប្រឆាំងនិងសេអ៊ីអាដែលកំពុងតែរៀបចំបង្កើតមជ្ឈមណ្ឌលមួយនៅប៉ាយ ហ្គាប់ Pine Gap ក្នុងតំបន់ប្រទេសអូស្ត្រាលីកណ្តាល Central Australia ។ តាមការនាំចេញ ប៉ាយហ្គាប់ជាស្ថានីយ៍ប្រើសំរាប់ជួយដល់ការបើកបរនាវា ដោយដំរង់រកទិសតាមរបៀបអូតូម៉ាត " គឺជារបៀបបើកបរយ៉ាងជាក់លាក់ណាស់ " ។ ប៉ុន្តែតាមពិត គេសង្ស័យថាសេអ៊ីអានិងប្រើស្ថានីយ៍ ប៉ាយ ហ្គាប់ ដើម្បីទាក់ទងជាមួយ-តារាវិទ្យាសាស្ត្រហើយនិងបញ្ជារទៅកាំជ្រួចដែលអាចបាញ់ទៅទ្វីបមួយទៅទ្វីបមួយទៀត បាន ICBM ។ ដើម្បីនិងបង្ហាញឱ្យឃើញថា គេមិនមែននិយាយលេងទេ ក្រុមអ្នកបះបោររបស់នេះបានដាក់គ្រាប់បែកកំទិចរោងចក្រធ្វើឈើមួយនៅ ប៊ុន ប៊ូរី - Bunbury ក្នុងរដ្ឋវ៉ែស្ទេន អូស្ត្រាលីយ៉ាខូចខាតស្រេច ។ តាមរយៈនៃមិត្តភក្តិ ហើយនិងឱកាសជ្រុងពុ ខ្ញុំអាចតាមដានចលនារបស់ជនជាតិអូស្ត្រាលីទាំងពីរនាក់-រហូតដល់ចាប់ពួកអ្នកនោះបានជាទីបញ្ចប់ ។ ដោយមានអ្នកទិញវិទ្យុខ្ញុំជួយប្រាប់ផង ខ្ញុំអាចតាមដានពួកក្រុមបះបោរទាំងនេះ ៣ នាក់ថែមទៀតដែលជាជនជាតិអាមេរិក ពេលដែលពួកនោះធ្វើដំណើរទៅកាន់រដ្ឋសៅ អូស្ត្រាលីយ៉ា South Australia ដល់កន្លែងនោះទើបភ្នាក់ងារសេអ៊ីអាចាប់យកពួកគេទៅ ។ ចុងខែវិច្ឆិកា ខ្ញុំទទួលការស្នើរពេញពីគឺម ហ្វាកណាប៊ី ឱ្យទិញគ្រឿងម៉ាស៊ីនសំរាប់ទូកក្តោង ណានុក ហើយទៅលេងវិស្សមកាលបើកបរទូកក្តោងជាមួយគាត់ហើយនិង រ៉ុននីន ។ អ្នកទាំងពីរនៅឯទីក្រុងសេប៊ូស៊ីទី Cebu City ក្នុងប្រទេសហ្វីលីពីន ខ្ញុំស្នើសុំការអនុញ្ញាត

00007926

Extracted from ERN: 00007904-00008067

00007927



យប់វិលត្រឡប់មកពី ការ៉ុល ហើយគាត់ក៏យល់ព្រម ។ ខ្ញុំលក់ឡានរកស៊ីចេញ ស្នើសុំលិខិតឆ្លងដែនមួយហើយចាកចេញពីវែលនៅថ្ងៃ ២៨ ខែធ្នូ ឆ្នាំ ១៩៧៧ ។ ខ្ញុំទៅដល់ទីក្រុងសានជុកនៅថ្ងៃ ១ ខែមករា ឆ្នាំ ១៩៧៨ ហើយបើកបរវាក្នុងចន្លោះប្រទេសហ្វីលីពីនកណ្តាលទៅរកទីក្រុងម៉ានីល ។

រ៉ុន ហើយនិង ឌីន ស្នើឱ្យខ្ញុំបើកបរទូកជាមួយគេតទៅទៀត ។ ខ្ញុំទាក់ទងទៅ ការ៉ុល វិញ ហើយនិយាយប្រាប់គាត់ថាខ្ញុំចង់នៅប្រទេសហ្វីលីពីនរហូតដល់ខែ ឧសភា ។ គាត់ក៏យល់ព្រមអនុញ្ញាតតាមសេចក្តីស្នើសុំរបស់ខ្ញុំ ។

មុនពេលដែលខ្ញុំត្រូវត្រឡប់ទៅវែលវិញ ខ្ញុំបានឮ គីម ហើយនិង រ៉ុននិយាយថាចារខ្លាចាំនឹងបើកបរទូកទៅហុងកុង ហើយនឹងវិលត្រឡប់មកវិញនៅខែកក្កដា អ្នកទាំងពីរនាក់ក៏បានស្នើឱ្យខ្ញុំធ្វើដំណើរជាមួយនឹងគេដែរ ។ ម៉្យាងទៀត រ៉ុន ក៏បានស្នើឱ្យខ្ញុំធ្វើដំណើរជាមួយគាត់ទៅកោះប៉ាឡាវ៉ាន់ Palawan រដ្ឋប្រ៊ូណាយ - Brunei ប្រទេសថៃ ហើយនិងត្រឡប់មកវិញនៅខែកញ្ញាឬតុលា ។ ខ្ញុំក៏បញ្ជាក់ប្រាប់ទៅវិញថាខ្ញុំអាចនឹងធ្វើបាន ។ ខ្ញុំក៏ត្រឡប់ទៅវែលវិញនៅដើមខែមិថុនា ឆ្នាំ ១៩៧៨ ។

ពេលដែលត្រឡប់ទៅវែលវិញ ខ្ញុំបានពត៌មានប្រាប់ គ្រីស រីឆាតស្វុន អំពីដំណើរដែល ឌីន ហើយនិង ប្រភណ្ឌាប៊ី បានស្នើឱ្យខ្ញុំធ្វើតាមទូកជាមួយគេ ។ ពីព្រោះខ្ញុំចង់បានការអនុញ្ញាតពីការ៉ុលសិនដើម្បីនឹងផ្អាកការងារខ្ញុំ ។

ថ្ងៃ ២៤ ខែមិថុនា គ្រីស នឹងធ្វើលិខិតណែនាំឱ្យខ្ញុំស្គាល់ម៉ាក់ម៉ាកគីនលី Chuck Mc Kinley ដែលជាជនជាតិអាមេរិក ពាក់សក្តិ ៣ សេរីរ៉ា ហើយធ្វើជាអ្នកជំនួយដល់ ការ៉ុល ។

Extracted from ERN: 00007904-00008067

00007928





នាក់ចាំកន្លែងលើ ក៏លើកចេញ ត្រូវលពុះព្រួយកកម្មមួយដែលគាត់ចង់ឱ្យខ្ញុំបំពេញឱ្យគាត់ នៅពេលដែលខ្ញុំបើកបរទូកក្តោងទៅថៃហើយនិងត្រឡប់មកវិញ ។ នៅក្នុងបេសកកម្មនេះ ត្រូវយកការឱ្យបានពីទីតាំងការពារសមុទ្ររបស់កម្ពុជា ដើម្បីឱ្យនាវា សេរីកាមួយចូលទៅដាក់ភ្នាក់ងារទៅក្នុងដែនដីកម្ពុជា ហើយនិងយកពួកនោះដើម្បីចេញមកវិញនៅដើមខែ មករា ឆ្នាំ ១៩៧៨ ។

សេរីកា មានពត៌មានខ្លះពុះហើយ ប៉ុន្តែភាគច្រើនជាពត៌មានចាស់ឬមួយដែក-ទៅលើការទ្យាំងស្ពាន ។ បេសកកម្មនេះមានពីរដំណាក់កាល ។ ពេលដែលសមុទ្រ ខ្ញុំបើកបរទូកទៅប្រទេសថៃ ខ្ញុំត្រូវបើកបរទូកនៅក្នុងដែនទឹកអន្តរជាតិ តាមជាំងទល់ដែនទឹកកម្ពុជា ។ ត្រូវថតរូបនាវានេសាទត្រីហើយនិងស្គាល់ទំលក់ភ្នាកាលវិទ្យុ ហើយនិងកំណត់មើលថាត្រូវប្រើប្រេក្វង់បរិក្ខារអ្វីបន្ទៀត នៅពេលធ្វើដំណើរត្រឡប់មកវិញ ។

នៅក្នុងបេសកកម្មនេះ ត្រូវថតរូបកោះនៅផ្នែកនិរតីនៃកម្ពុជា ដែលនៅជាប់ជិតនិងទល់ដែនកម្ពុជា-យួន ហើយនិងដែនទឹកអន្តរជាតិ ។ ហើយនិងកោះនៅផ្នែកខាងលិច ជាប់ជិតនិងទល់ដែនថៃ ។ ត្រូវថតរូបមុនហើយនិងក្រោយពេលព្រឹកព្រលឹមបន្តិច ដោយប្រើបច្ចេកទេសផ្តេក ។ ហើយត្រូវថតថានៅក្នុងចន្លោះពេលដែលទូកចូលមកជិត ។ យ៉ាងដូច្នេះ ខ្ញុំអាចប្រើលើទឹកកំណត់-កន្លែងថតនីមួយៗ ហើយនិងមុំដែលត្រូវថតរូប ។ ការយករូបថតនោះទៅផ្តិតហើយ សេរីកា អាចនិងកំណត់បានថាកន្លែងណាជាទីតាំងកាំភ្លើងធំៗ ទើបមានធុនធ្ងន់ កន្លែងបង្ហាញ ហើយនិងកំណត់មើលផងទៀតថាកន្លែងណាជាទីតាំងយោធា ។

ខ្ញុំត្រូវថតរូបនាវានេសាទត្រីណាមួយដែលខ្ញុំជួបប្រទះ ។ ថតទាំងផ្នែក-

Extracted from ERN: 00007904-00008067

ទៅនិងរូបថតដែលខ្ញុំយកបាន ពេលដែលខ្ញុំធ្វើដំណើរទៅខាងជើង ។ យ៉ាងដូច្នេះ ភាពអាចនិងពិនិត្យមើលទៅអាកាសដែលមានទៅលើនាវានោះ ។ ជាការបញ្ជាក់ បន្ថែមដល់ដែលបានដឹងហើយជាការពិតប្រាកដ ។ រូបថតទាំងអស់ពុំនិងផ្តល់ពត៌មានឱ្យ លោកស៊ីអាបានប្រាប់គ្រប់ទៅនិងរៀបចំថាមួយមានរូបរៀងខាងក្រៅដូចគ្នានិងនា វាពេលទៅក្រៅនៃរូបថត ។

តាមការសង្ស័យរបស់លោកស៊ីអា កម្ពុជាច្បាស់ជាមានការកែប្រែគ្រឿងគ្រឿងផ្ទាប់ - ហើយនិងបាច់ស្ពានយ៉ាស៊ីននានាទៅពួកទឹក ក្នុងតំបន់ទាំងដែលទឹកមើលទៅឃើញនិងតាមផ្លូវ ដើមកំពង់មានការវាយលុកកាត់ទាំងដែលនោះ ។ ប្រាសាទប្តាប់ទៅពួកទឹកដែល- អាចមានគ្រប់ប្រាប់ក្នុងតាមដែលក្រុងទៅនិងប្រាប់ពួកយាត្រាទៅលើទឹកដែល អាចឃើញកាត់ក្នុងទំពាង គ្រូគ្រឿងបណ្តាលអ្វីពុំទៀតដែលក្រុមដំរាប់ទាលានត្រី ។ ខ្ញុំត្រូវពិនិត្យមើលរឿងនេះនិងបានដាក់ច្បាស់ ។ ដោយហេតុការសង្ស័យយ៉ាងនេះ ហើយបានជា លោកស៊ីអាត្រូវប្រើខ្ញុំរក្សាទុកការ ពីព្រោះវាត្រូវនិងពួកយ៉ាស៊ីន ផ្សេង ហើយម៉្យាងទៀតខ្ញុំរក្សានូវការកំពុង មិនអាចឱ្យតាំងការចាប់បានទេ ។

នៅក្នុងរបាយការណ៍ខ្ញុំបានដឹងច្រើនរឿងមានការធ្វើដំណើរទៅកាន់រូបភាពដែល ប្រើនៅក្នុងតំបន់នោះ ដើម្បីនិងធ្វើការទាក់ទងគ្នាពីនាវាមួយទៅនាវាមួយទៀត ហើយនិងពីនាវាទៅដែនគោក ។ លោកស៊ីអាត្រូវដកស៊ីគរឿងអស់នេះឱ្យបានច្បាស់ លាស់មុននិងបញ្ជូនឆ្លាក់មករយកដែនដីកម្ពុជា ។ យ៉ាងដូច្នេះនាងថា លោកស៊ីអាអាច ប្រើខ្លួនធ្វើការចារកម្មជាមួយនិងនាវាលេខទៅក្រៅទឹកកម្ពុជា ហើយនិងសាមីដំណឹងពួកទៅលើ- ដែនគោកបាន ។

គ្រឿងបរិក្ខារផ្សេងៗទៀតដែលត្រូវរៀបចំដាក់ទៅលើទូកទៅប្រទេសថៃ

ទាំងនិងគម្ពុជាក្រោមឲ្យស្ទាក់សញ្ញាវិទ្យុ ត្រូវរលកអាកាស ហាងពីរលកអាកាសខ្លីទម្លាក់

រលកអាកាសខ្លីម៉ែតទែន ។ ត្រូវរៀបចំដាក់ខ្សែអាកាសចំរង់ទិសទៅលើភ្នំ

ដើម្បីរៀបចំរកប្រភពផ្សាយរបស់ខ្លួនទៅលើផែនទី ហើយនិងរៀបចំដាក់ប្រដាប់ចាប់

បញ្ជូនរបស់ខ្លួន ដើម្បីឲ្យការផ្សាយទាក់ទងគ្នាឲ្យបានជានិច្ចជាកាល ។ ចេស ស៊ីអា

និងរៀបចំដាក់គ្រឿងវិទ្យុចំរាញ់ ហើយនិងប្រដាប់បើកបទទូរជាររបៀបអក្សរម៉ូស-

ថៃម
មួយទៀត " ប្រដាប់បើកបទនេះអាចរបៀបស៊ូរ៉េប៉ុក្កាទាំងពួកក៏ប្រាប់ឲ្យបើកបទបាន "

យ៉ាងងាកណាក់ណាស់ " ។

ចេះជាមេរកកម្មវិធីស្ដ្រីបានទទួលពី ណាក់ ចាក់ គីនលី ។ ណាក់បានទាំងផ្ដល់

ឲ្យខាងខ្ញុំប្រជុំផងហើយនិងភាពដែលធ្វើអង្គការភ្នាក់ងារ ស៊ីអា ដែលខ្ញុំត្រូវធ្វើសេចក្ដីរាយការ

ទៅទៅបន្ទាប់កនផង ។ ពីរបាក់បន្ទាប់ពីឆ្នាំ ណាក់ហ្គ្រី ២ ស៊ីអា ឈ្មោះ

ចេម ឈេរីញ៉ូត James Aniott ។ ខ្ញុំត្រូវជួបទាក់ទងនិង-

ភ្នាក់ងារនេះជាមនុស្សដែលខ្ញុំត្រូវឲ្យទៅការក្រៅខ្លួនដើម្បីរង្វង់ទីកន្លែងសណ្ឋាគារ ក្រេស

Grace Hotel នៅពេលមុនម៉ោង ១២ រំលងថ្ងៃត្រង់ ។ នៅក្នុងការនោះ

ខ្ញុំត្រូវធ្វើឲ្យណាត់មកជួបនិងខ្ញុំនៅក្រៅខ្លួនច្បាប់ទៅម៉ោង ៦ ល្ងាច ។

ដល់ពេលដើម្បីជួបទាក់ទងនិងគ្នារួចហើយ ភ្នាក់ងារ ស៊ីអា ត្រូវបំផុសឲ្យការមក

ឲ្យខ្ញុំ ពត៌មានប្រាប់ខ្ញុំពីការផ្លាស់ប្ដូរស្ថិតនៅក្នុងបេសកកម្មខ្ញុំ ហើយនិងបញ្ជូនសេចក្ដី-

រាយការណ៍របស់ខ្ញុំទៅឲ្យ ណាក់ ចាក់ គីនលី ។ ឈេរីញ៉ូតត្រូវរៀបចំជាស់ថែង

ដាក់គ្រឿងសំភារៈបច្ចេកទេសមកខ្ញុំ ហើយនិងជួយនាំខ្ញុំទៅវិញនូវរាល់អ្វីៗផ្សេងទៀតៗ

កាលណារៀបចំគ្រប់ក្លាក្រោយហើយ ខ្ញុំត្រូវរៀបចំផ្លូវបើកបទទូរ ហើយនិងកំណត់ពេល

ម៉ោងដែលត្រូវទាក់ទងតាមវិទ្យុជាមួយនិងណាត់ ។ បើសិនជាបានការពិតយ៉ាងនេះ

នៅក្នុងការបំពេញបេសកកម្មខ្ញុំ ត្រូវកំណត់កន្លែងណាមួយដែលខ្ញុំត្រូវបញ្ជូនពត៌មាន-របស់ខ្ញុំ ។ ឬមួយនៅក្នុងឃ្លាំងសមុទ្រថែតាមរយៈនៃនាវាណាមួយទៀត ឬមួយនៅរន្ធ្រប្រៀណាយ ។

ខ្ញុំបានបញ្ជាក់ប្រាប់ទៅ ម៉ាក់ គីនលី ថាខ្ញុំមិនអាចនឹងបំពេញបេសកកម្មបានទេ - បើគ្មានការយល់ព្រមពី វ៉ុន ឌីន ។ គាត់ក៏ឆ្លើយមកខ្ញុំវិញថា វ៉ុន ឌីន មុខជា-នឹងសុខចិត្តហើយ បើសិនជាសេអ៊ីអាបង់លុយ ៥០០០ ដុល្លាឱ្យទៅគាត់សំរាប់ប្រើប្រាស់ទុកយ៉ាងខ្លះ ។ ម្យ៉ាងទៀតបេសកកម្មនេះគ្មានគ្រោះថ្នាក់អ្វីទេ ។

រួចហើយទើប ឆាក់ ម៉ាក់ គីនលី ប្រាប់បញ្ជាក់មកខ្ញុំថា សេអ៊ីអានឹងយកពត៌មាន-របស់ខ្ញុំមកប្រើសំរាប់ធ្វើអ្វី ។

នាវាពិសេសដែលសេអ៊ីអាត្រូវប្រើនៅខែមករា ឆ្នាំ ១៩៧៤ ជានាវាមួយធ្វើពីជាតិជ័រផ្លាស់ទិករឹងមាំ មានរាងដូចជានាវានេសាទត្រីកម្ពុជា ។ ផ្នែកខាងលើរៀបចំនៅលើតួនាវាមួយដែលជានាវាយាមល្បាត អ៊ីតាលី មានល្បឿន-ខ្លាំងអាចទៅរឹងដល់ទៅ ៦៥ គ.ម ក្នុងមួយម៉ោង តាមកម្លាំងជាក់ស្តែងនៃម៉ាស៊ីនប្រើសំរាប់ទាញវា ។ នាវានេសាទត្រីនេះត្រូវផ្ទុកគ្រឿងគ្រៅអប្ប៉ាណូផ្សេងៗសំរាប់ធ្វើការតាមផ្លូវ ដូចជារ៉ាដារ វិទ្យុ និងសូណារ "សូណារប្រើជារបៀបរ៉ាដារ ប៉ុន្តែវាប្រើសំរាប់មើលរបស់នៅក្រោមទឹក" ។ ហើយវាត្រូវបើកបរនៅក្នុងចំណោមនាវាដទៃទៀតកុំឱ្យគេចាប់ភ្លឹកបាន ។ ក្រុមនាវិកវា គឺសុទ្ធតែជាភ្នាក់ងារសេអ៊ីអាជនជាតិកម្ពុជា ដែលបានទទួលការបង្ហាត់អប់រំយ៉ាង-ថ្មីកខាងផ្នែកប្រើប្រាស់វិទ្យុ ហើយនិងរលកអាកាសផ្សេងៗ ។ នាវាសេអ៊ីអាត្រូវដឹកនាំភ្នាក់ងារទៅទម្លាក់ទៅជិតកោះដែលបានជ្រើសរើសតាមការពិនិត្យពិចារណា

Extracted from ERN: 00007904-00008067

មើលរូបថតយកពីបេសកកម្មខ្ញុំ ។ ត្រូវដាក់ភ្នាក់ងារឱ្យទៅប្រតិបត្តិការតែម្នាក់ឯងឬជាគូ ។ ភ្នាក់ងារទាំងឡាយត្រូវពិនិត្យមើលយ៉ាងម៉ត់ចត់ទីតាំងផ្សេងៗនៅលើកោះ ។ បើសិនជាអាចធ្វើបាន ត្រូវរៀបចំដាក់គ្រឿងគ្រៅវិទ្យានសញ្ញាភ្លើងនៅជិតខ្សែអាកាសនៃស្ថានីយ៍វិទ្យុ ។ កាលណាគេបញ្ជាក់ឱ្យវាដើរ គ្រឿងអស់នោះនឹងធ្វើឱ្យវិវត់ប្រព័ន្ធវិទ្យុមើលរបស់កម្ពុជា ។ ភ្នាក់ងារសេអ៊ីអាត្រូវដាក់នៅលើកោះគ្រឿងប្រើប្រាស់ជាសញ្ញាជួយដល់ការបើកបរទូកដែលដើរតាមរលកអាកាសខ្លី ហើយគេអាចនឹងបញ្ជាបិទបើកវាពីចម្ងាយបាន ។ ភ្នាក់ងារម្នាក់ៗត្រូវពិនិត្យមើលកោះឱ្យបានល្អិតល្អន់ ហើយមកជួបនឹងទូកវិញ កាលណាបំពេញបេសកកម្មចប់ ។

នាវានេសាទត្រីសេអ៊ីអាត្រូវថតសម្លេងទាក់ទងគ្នាតាមវិទ្យុនៅក្នុងតំបន់នោះ ហើយប្រើគ្រឿង សូណារ ដើម្បីនិងកំណត់មើលថាតើមានមីននៅក្នុងទឹកឬទេ ។ តាំងពីពេលដែលភ្នាក់ងារចុះពីទូករហូតដល់ពេលត្រឡប់មកវិញ ប្រតិបត្តិការនេះ-ត្រូវចាមចារពេលវេលាអស់ ៥ ថ្ងៃ ។ ពត៌មានដែលយកបានទាំងប៉ុន្មានត្រូវបញ្ជូនវាផ្ទាល់ទៅសេនាធិការសេអ៊ីអា ខាងចាត់ចែងផែនការនៅអាមេរិក សំរាប់ប្រើប្រាស់វានៅក្នុងផែនការចំពោះកម្ពុជា ។ គឺរៀបចំទីលផ្លូវបើក (ដែនទឹកកម្ពុជា។) បរទូកទៅរកដែនសមុទ្រដោយគ្មានគ្រោះថ្នាក់នៅក្នុងបេសកកម្មរបស់ខ្ញុំ ហើយនិងនាវានេសាទត្រីខ្លួនក្លាយគ្រាន់តែជាមួយផ្នែកនៃប្រតិបត្តិការដែលសេអ៊ីអាកំពុងតែរៀបចំដើម្បីយកពត៌មានឱ្យបានច្រើនបំផុតពីកម្ពុជា ។

ណាក់ ម៉ាក់គីនលី បាននិយាយប្រាប់មកខ្ញុំផែនការខ្លះៗរបស់សេអ៊ីអាចំពោះកម្ពុជា ហើយតើវាទាក់ទងយ៉ាងណានឹងបេសកកម្មខ្ញុំ ។ គោលបំណងរួមរបស់សេអ៊ីអា គឺ

ធ្វើយ៉ាងម៉េចឱ្យមានរដ្ឋាភិបាលមួយរបបអាមេរិកត្រឡប់មកកាន់អំណាចនៅកម្ពុជាវិញ ។ វាអាចនឹងទៅជាយ៉ាងនេះបានតែការណ៍ក្រោយពីមានរដ្ឋប្រហារមួយ ។ ប៉ុន្តែសេអ៊ីអាមិនហ៊ានល្បួកដែលចូលផ្ទាល់ទេ ពីព្រោះសេអ៊ីអាមានឈ្មោះអាក្រក់ខ្លាំងពេក-ថាបានចូលជ្រៀតជ្រែកក្នុងបញ្ហាផ្ទៃក្នុងនៃប្រទេសដទៃទៀត ជាពិសេសនៅប្រ-ទេសឈីលី ។ ម្យ៉ាងទៀត សាធារណមតិនៅប្រទេសអាមេរិកកំពុងតែចោទប្រកាន់យ៉ាងខ្លាំងដល់សិទ្ធិអំណាចនៃសេអ៊ីអាផង ។ ដូច្នេះហើយចំពោះប្រតិបត្តិការទាំងប៉ុន្មាននៅកម្ពុជា គឺត្រូវតែមានជនជាតិកម្ពុជាជាអ្នកចាត់ចែងវា ។

អ្នកភៀសខ្លួនជនជាតិកម្ពុជាមួយចំនួននៅញូវ អ៊ែរលីន New Orleans កំពង់តែធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងសេអ៊ីអា ដើម្បីនឹងរៀបចំបង្កើតរដ្ឋាភិបាលបរទេសមួយ ហើយនិងរៀបចំបង្ហាត់បង្រៀនភ្នាក់ងារដោយមានការជ្រោមជ្រែងពីសេអ៊ីអា ។ ពួកអ្នកទាំងអស់នេះបានគិតគូរចាត់ចែងផែនការមួយចំនួនដើម្បីសំរេចទៅធ្វើរដ្ឋប្រហារនៅកម្ពុជាឱ្យបាន ។ ប៉ុន្តែដោយខ្វះពត៌មានជាក់ស្តែងពីក្នុងកម្ពុជា ពួកគេ-មិនអាចតណ្តុះបណ្តាលផែនការអស់នោះសោះ ។ គេត្រូវការដឹងពត៌មាននៅគ្រប់ផ្នែក ទាំងខាងសេដ្ឋកិច្ច នយោបាយ កសិកម្មហើយនិងយោធា ។

សេអ៊ីអាបានរៀបចំប្រតិបត្តិការមួយដើម្បីនឹងយកពត៌មានអស់នេះ ។ ប្រតិបត្តិការសេអ៊ីអាត្រូវចាប់ផ្តើមនៅពាក់កណ្តាលខែកុម្ភៈ ឬនៅខែមិនា ឆ្នាំ ១៩៧៨ កាលណានាវានេសាទត្រីក្លែងក្លាយរបស់សេអ៊ីអាបានពិនិត្យមើលផ្លូវបើកបរទូកចូលមកក្នុងឈូង-សមុទ្រកម្ពុជារួចសព្វអស់ហើយ ។ ភ្នាក់ងារសេអ៊ីអា ១០០ នាក់ដែលជាជនជាតិកម្ពុជាត្រូវឆ្លងកាត់ទល់ដែនថៃ ហើយនិងធ្វើដំណើរទៅកន្លែងកំណត់សំរាប់ម្នាក់ៗ-ហើយនិងយកការឱ្យបាន ។ ភ្នាក់ងារភាគច្រើនត្រូវយកទៅជាមួយខ្លួនប្រដាប់

Extracted from ERN: 00007904-00008067

មួយតួបសំរាប់បញ្ជូនសញ្ញាវិទ្យុ ហើយនិងរូបថតទៅតារាវិទ្យាសាស្ត្រ~~ដែលនិង~~ ដែលនិងបញ្ជូនវាត្រឡប់មកស្ថានីយ៍សេអ៊ីអាមួយនៅប្រទេសថៃខាងត្បូង ។ ប៉ុន្តែប្រដាប់នោះអាចទទួលបានតែកញ្ចប់សញ្ញាវិទ្យុជាទូរលេខទេ ។

ភ្នាក់ងារម្នាក់ៗត្រូវយកទៅជាមួយខ្លួនគ្រឿងសំភារៈស្បៀងសំរាប់រស់នៅ - បាន ១២ អាទិត្យ ត្រូវកាន់កាំភ្លើង AK ៤៧ ធម្មតា ហើយនិងស្លៀកពាក់ខោអាវតាមរបៀបកម្ពុជា ។ ភ្នាក់ងារខ្លះត្រូវកាន់វិទ្យុទាក់ទងឆ្ងាយដើម្បីធ្វើការទាក់ទងវិទ្យុផ្ទាល់ជាមួយនិងស្ថានីយ៍សេអ៊ីអានៅថៃ ។ នៅក្នុងចំនួនភ្នាក់ងារទាំង ១០០ នាក់ អ្នកខ្លះត្រូវធ្វើដំណើរទៅឆ្នេរសមុទ្រ ដើម្បីនិងពិនិត្យមើលទីតាំងយោធា ហើយនិងរកមើលកន្លែងណាដែលអាចទទួលស្បៀងហើយនិងគ្រឿងសំភារៈតាមនាវាកុម្ម៉ង់បាន ។ តាមណាកំណត់រកមើលកន្លែងអស់នោះបានហើយ ភ្នាក់ - ងារចំពួកនេះត្រូវធ្វើដំណើរចូលទៅក្នុងដីគោក រៀបចំមើលកន្លែងដាក់វិទ្យុទាក់ទង ដាក់ស្បៀង ហើយនិងផ្លូវគេចខ្លួនរត់មកឆ្នេរសមុទ្របាន ។

ប៉ុន្តែភាគច្រើនត្រូវចូលទៅក្នុងកម្ពុជាកណ្តាល ហើយនិងរៀបចំកន្លែងរស់ - នៅ ១២ អាទិត្យកុំឱ្យគេមើលឃើញ ព្រមទាំងរៀបចំគ្រឿងសំភារៈទាក់ទងផ្សេងៗ ។ ត្រូវពិនិត្យមើលកន្លែងណាល្អសំរាប់លាក់ស្បៀង ហើយនិងកន្លែងណាមានវាលធំល្មមសំរាប់ទម្លាក់មនុស្ស ហើយនិងស្បៀងតាមយន្តហោះ ។ ត្រូវរាយការណ៍អំពីលក្ខណៈទូទៅនៅក្នុងតំបន់ខ្លួន ហើយនិងអ្វីៗប្លែកខុសធម្មតា រាយការណ៍ឱ្យបានល្អិតល្អន់ ។ ពួកអ្នកអស់នោះត្រូវបញ្ជូនរូបថតពីព្រឹត្តិការណ៍ទាំងឡាយ ។

ភ្នាក់ងារមួយក្រុមទៀតត្រូវធ្វើដំណើរទៅកាន់ទីប្រជុំជនធំៗ ដើម្បីនិងរកមើលមជ្ឈមណ្ឌលហើយនិងខ្សែគមនាគមន៍ទាក់ទងគ្នា ។ ត្រូវដាក់គ្រឿងលប -

00007934

Extracted from ERN: 00007904-00008067

ស្ទាប់ការទាក់ទងគ្នា ឬមួយពិនិត្យមើលទាំងឲ្យបានច្បាស់លាស់ដើម្បីនឹងរៀបចំវិធានការ សំរាប់ទៅថ្ងៃក្រោយទៀត ។ ភ្នាក់ងារមួយក្រុមទៀតដែលមានការពិសោធ ខាងផ្នែកឃោសនាត្រូវធ្វើដំណើរទៅតំបន់សមរភូមិហើយបញ្ជូនពត៌មានឲ្យបានច្បាស់លាស់ ពីសភាពការឃោសនារវាងកម្ពុជានិងយួន តើនរណាចាញ់ នរណាឈ្នះ ។ ពត៌មានទាំងអស់នេះត្រូវបញ្ជូនទៅស្ថានីយ៍គមនាគមន៍សេអ៊ីអានៅប្រទេសថៃខាងត្បូងៗ រួចហើយស្ថានីយ៍នៅថៃនឹងបញ្ជូនបណ្តាក់ទាំ ទៅមជ្ឈមណ្ឌលប្រតិបត្តិការរបស់សេអ៊ីអានៅ សហរដ្ឋអាមេរិក សំរាប់ឲ្យគេរៀបចំវិភាគមើលទាំ រៀបចំកម្លាំងការទុក-ហើយនឹងប្រើប្រាស់ពត៌មានអ្វីៗដែលត្រូវការ ។ តាមរយៈនៃក្រុមពួកកម្ពុជាយ៉ាង សកម្មនៅញ៉ូវអិវែលីន សេអ៊ីអាកំពុងតែបើកយុទ្ធនាការមួយតាមការដែល វាយ-ប្រហារកម្ពុជា ហើយនឹងបណ្តុះបណ្តាលឲ្យសាធារណៈជនទាំងឡាយស្រឡាញ់ចូលចិត្ត គាំទ្រជនភៀសខ្លួន ។ ខាងផ្នែកអន្តរជាតិ សេអ៊ីអាកំពុងតែធ្វើការឃោ-ឃ្មុះឃ្មោយឲ្យចិនដកជំនួយចេញពីកម្ពុជា ។ ទាំងការគាំទ្រជាផ្លូវចិត្ត ទាំងទីប្រឹក្សាៗ

នៅក្នុងប្រទេសលោកសេរីទាំងឡាយ ត្រូវផ្សាយអត្ថបទតាមតាវែតហៅ ឲ្យជនជាតិកម្ពុជារួបរួមគ្នា ហើយនឹងគាំទ្ររដ្ឋាភិបាលនិរទេសមួយ ។ ភ្នាក់ងារកម្ពុជា ដែលបានទទួលការអប់រំពីសេអ៊ីអាត្រូវធ្វើដំណើរទៅកាន់ទីក្រុងធំៗនៃលោកខាងលិច -ដើម្បីនឹងទទួលការគាំទ្រយ៉ាងនេះ ។ ត្រូវរៃអង្គាសលុយកាក់ ហើយនឹងជ្រើសរើស អ្នកស្ម័គ្រចិត្តឲ្យចូលធ្វើជាទាហានសំរាប់រៀបចំរដ្ឋប្រហារដណ្តើមយករដ្ឋអំណាច ។ សេអ៊ីអាត្រូវរៀបចំបង្ហាត់អប់រំឃោសនាឲ្យជនជាតិកម្ពុជានៅក្នុងប្រទេសនិមួយៗ ។ សេអ៊ីអាសង្ឃឹមថាអាចនឹងជ្រើសរើសកងទ័ពបានពី ១២០០០ ទៅ ១៥០០០ នាក់ បើ រាប់កម្លាំងនៅគ្រប់ប្រទេសទាំងអស់ ។ អ្នកស្ម័គ្រចិត្តខ្លះត្រូវទៅទទួលការអប់រំ-

Extracted from ERN: 00007904-00008067

ពិសោធនៅអាមេរិកផង ។

ខែតុលា ឆ្នាំ ១៩៧៩ ត្រូវបង្ហាត់ហ្វឹកហ្វឺនភ្នាក់ងារនិយោជន ៥០០ នាក់រួចជាស្រេចៗ ហើយនៅខែមករា ឆ្នាំ ១៩៨០ ត្រូវបង្ហាត់និយោជនភ្នាក់ងារ ៦០០ នាក់ទៀត ។ ភ្នាក់ងារចុងក្រោយនេះត្រូវទទួលការអប់រំយ៉ាងខ្លីពីសេអ៊ីអា គឺអស់តែ ៣ ខែទេ ។

ត្រូវបន្តនិយាយភាក្រក់តាមការស៊ែកពីកម្ពុជា នៅពេញមួយឆ្នាំ ១៩៧៩ ដោយប្រើពត៌មានផ្សេងៗដែលផ្ដល់មកពីសេអ៊ីអា ។

កាលណាភ្នាក់ងារភាគច្រើននៅក្នុងចំណោមអ្នកទាំង ១១០ នាក់ដែលបញ្ជូនទៅកម្ពុជាត្រឡប់មកវិញនៅខែមិថុនា ឆ្នាំ ១៩៧៨ ពួកអ្នក[ត្រា៖]អាចនិងរាយការណ៍ផ្ទាល់ ។ ហើយសេអ៊ីអានិងទទួលបានពត៌មានគ្រប់គ្រាន់ដើម្បីចាប់ផ្ដើមរៀបចំផែនការល្បិចល្បួនសំរាប់វាយដណ្ដើមយកអំណាច ។ សេអ៊ីអាបានរៀបចំផែនការដើម្បីដាក់ប្រតិបត្តិការមួយដើម្បីបញ្ជូនភ្នាក់ងារមកយកការម្ដងទៀត នៅខែតុលា ឆ្នាំ១៩៧៩ ដោយប្រើភ្នាក់ងារជាង ៥០០ នាក់ ។ ពួកអ្នកនេះអាចនិងបញ្ជូនពត៌មានសំរាប់ឲ្យសេអ៊ីអា ហើយនិងក្រុមញ៉ូវអ៊ិនលីនកំណត់មើលកម្លាំងកម្ពុជាបានជាប្រចាំថ្ងៃ ។ ភ្នាក់ងារសេអ៊ីអាទាំង ៥០០ នាក់ត្រូវចូលមកកម្ពុជាតាមផ្លូវទឹក ឬមួយឡើងយន្តហោះពីថៃ ដើម្បីនិងចុះឆ័ត្រយោងនៅលើតំបន់ម្នាក់ៗ ។ ត្រូវរៀបចំកន្លែងទាក់ទងគមនាគមន៍ ហើយនិងចាប់ផ្ដើមបញ្ជូនពត៌មានល្បិចល្បួនពីតំបន់ខ្លួន ព្រមទាំងអនុវត្តភារៈកិច្ចផ្សេងៗតាមការណែនាំចំពោះម្នាក់ៗ ។ ភ្នាក់ងារភាគច្រើនត្រូវបំពេញបេសកកម្មដោយធ្វើការជាគូៗ ។ ភ្នាក់ងារខ្លះត្រូវខិតខំសង្កេតមើលរបៀបរស់នៅធ្វើការប្រចាំថ្ងៃនៃកម្មាភិបាលនៅក្នុងកងទ័ពក្រោមនិងរដ្ឋាភិបាល ។ ភារកិច្ចនេះពិបាកពិតមែនហើយ ប៉ុន្តែចាំបាច់ត្រូវតែដឹងថាអ្នកអស់នោះនៅទីណាមុននិងធ្វើ

Extracted from ERN: 00007904-00008067

រដ្ឋប្រហារ ។ ភ្នាក់ងារមួយចំនួនត្រូវខិតខំធ្វើការទាក់ទងជាមួយនិងជនខ្លះ ដែលមានសមានចិត្តស្រឡាញ់សោកសេរី ។ អ្នកអស់នេះត្រូវរាយការណ៍ពីសន្ធានចិត្តនៃប្រជាជនចំពោះរដ្ឋាភិបាលថ្មី ។

បុគ្គលិកដែលបានទទួលការអប់រំយោធាត្រូវធ្វើដំណើរទៅកាន់តំបន់សមរភូមិហើយ និងធ្វើការប៉ាន់ស្មានមើលសភាពការណ៍យោធាឱ្យបានយ៉ាងច្រើនបំផុត ។ មួយក្រុម-ពិសេសត្រូវខិតខំលបស្ដាប់មើលប្រពន្ធ័គមនាគមន៍ ទូរស័ព្ទហើយនិងវិទ្យុ ។

នៅក្នុងផែនការសេអ៊ីអា ពត៌មានខាងផ្នែកសេដ្ឋកិច្ចហើយនិងកសិកម្មក៏ចាំបាច់មានដែរ ហើយភ្នាក់ងារទាំងឡាយត្រូវខិតខំពិនិត្យរកមើលជម្រុកស្រូវ ហើយនិងជំរុំនានា ។ ត្រូវប៉ាន់ស្មានមើលប្រពន្ធ័ចាត់ចែងទឹក ហើយនិងសមត្ថភាពខាងសំរាប់ផ្តល់ទឹកធ្វើស្រែ - នៅក្នុងតំបន់នីមួយៗ ។ ត្រូវប៉ាន់ស្មានឱ្យបានប្តឹមត្រូវ ផលស្រូវទាំងដើម ទាំងចុងឆ្នាំ ហើយនិងទំហុំផ្ទៃដីសំរាប់ដាំដំណាំអ្វីផ្សេងៗទៀត ។ ត្រូវកត់សំគាល់ផ្លូវថ្នល់ហើយនិងគមនាគមន៍នៅក្នុងតំបន់នីមួយៗ ហើយរកមើលកន្លែងណាដែលមានការរែករនង ហើយនិងទីតាំងកងទ័ព ។

ពត៌មានល្អិតល្អន់យ៉ាងនេះត្រូវផ្តល់មកឱ្យបុគ្គលិកចាត់ចែងផែនការសេអ៊ីអាជារៀងរាល់ថ្ងៃ ។ ចំពោះសេអ៊ីអាហើយនិងក្រុមជនភៀសខ្លួននៅញូវ អ៊ិងលីន ពេលវេលាល្អបំផុតសំរាប់ធ្វើរដ្ឋប្រហារនៅកម្ពុជា គឺកាលណាប្រទេសនេះចុះខ្សោយដោយសារសង្គ្រាមជាទ្រង់ទ្រាយធំជាមួយនិងយួនម្ដងកាលណាប្រទេសនេះអត់បាយ ។ ចំពោះប្រទេសដែលពឹងផ្អែកទៅលើកសិកម្មយ៉ាងនេះ ប្រទេសនោះនឹងចុះខ្សោយមិនខាន កាលណាមានផលដំណាំអាក្រក់ដោយសារសត្វល្អិតឬរោគដំណាំផ្សេងៗ ហើយកាលណាគ្មានស្រូវបង្ការទុកឱ្យបានគ្រប់គ្រាន់ ។ សភាពការណ៍ល្អបំផុត គឺនៅពេល

Extracted from ERN: 00007904-00008067

ណាដែលកម្ពុជាជួបប្រទះនិងគ្រោះថ្នាក់ទាំងពីរ~~ប្រការ~~ ប្រភេទ ។

សេអ៊ីអាដឹងច្បាស់ថាយួននឹងត្រូវការរៀបចំបំពាក់សាស្ត្រាវុធជាច្រើនម្តង - ទៀតនៅឆ្នាំ ១៩៧៨ - ៧៩ ពីព្រោះសំភារៈទាំងប៉ុន្មានដែលនៅសល់ពីសង្គ្រាម ឥណ្ឌូចិនពេលដែលអាមេរិកលះបង់វា ត្រូវវានេះវាចាស់ពុកផុយខ្ទិចខ្ទីអស់ហើយ ។ សូវៀត មុខជានឹងបញ្ជូនអាវុធមកយួនថែមទៀត តើបញ្ជូនវាដល់កំរិតណា ។ សេអ៊ីអា អាចនឹងយល់ដឹងផែនការសូវៀតចំពោះហាណូយបាន តាមរយៈទីភ្នាក់ងារសេអ៊ីអា នៅម៉ូស្គូ ។ ហើយសេអ៊ីអានឹងយកព័ត៌មាននេះមកប្រើសំរាប់ប៉ាន់ស្មានមើលថា តើនៅពេលណាយួននឹងវាយចូលលុកយ៉ាងខ្លាំងមកកម្ពុជា ។

តាមធម្មតា សកម្មភាពយោធាតែងតែមានលក្ខណៈខ្លាំងនៅរដូវប្រាំង ។ នៅពេលនេះហើយ ដែលជំនួយយោធារបស់សូវៀតទៅយួននឹងកំរិតគ្រោះខ្លាំងដល់ - សង្គ្រាមរបស់សេអ៊ីអានៅកម្ពុជា ។ បើសូវៀតបញ្ជូនសព្វាវុធថ្មីៗមកហាណូយ នៅចំណាក់កាល ១៩៧៨ - ១៩៧៩ យួននឹងចាប់វាយលុកចូលយ៉ាងខ្លាំងនៅរយៈកាលខែធ្នូ ឆ្នាំ ១៩៧៩ ទៅខែមិនា ឆ្នាំ ១៩៨០ ។ តាមរយៈភ្នាក់ងារសេអ៊ីអា នៅម៉ូស្គូយកព័ត៌មានបានថាយួននឹងវាយលុកនៅពេលណាហើយ សេអ៊ីអាអាចនឹងរៀបចំផែនការសំរាប់ធ្វើសង្គ្រាមដំណាលគ្នា ។ ដោយពិនិត្យមើលកត្តាផ្សេងក្នុង ប្រចាំថ្ងៃដែលផ្តល់មកពីភ្នាក់ងារនៅកម្ពុជា សេអ៊ីអាអាចនឹងជ្រើសរើសថ្ងៃណាដែលប្រសើរល្អសំរាប់ប្រតិបត្តិការ ។ បើសិនជាសកម្មភាពការកសិកម្មបណ្តាលឱ្យកម្ពុជាចុះខ្សោយ ពេលដែលត្រូវធ្វើការទប់ទល់នឹងយួនថែមទៀត សេអ៊ីអាអាចនឹងផ្លាស់ប្តូរថ្ងៃសង្គ្រាមទៅតាមកាលៈទេសៈនេះ ។

ត្រូវប្រុងប្រយ័ត្នរើសថ្ងៃខែធ្វើសង្គ្រាមឱ្យបានម៉ត់ចត់ម៉ែនទែន ពីព្រោះ

Extracted from ERN: 00007904-00008067

00007939





រដ្ឋាភិបាលថ្មីត្រូវតែផ្តើមរដ្ឋអំណាចយ៉ាងឆាប់រហ័ស ទាំងខាងផ្នែកនយោបាយ យោធា ហើយនិងសេដ្ឋកិច្ច ។ ដោយតាមដានមើលទីស្នាក់អាស្រ័យហើយនិងសកម្មភាពកម្មាភិបាលនៅក្នុងបក្សហើយនិងកងទ័ពយ៉ាងជាក់ច្បាស់ សេអ៊ីអានិងចាប់ខ្លួនពួកអ្នកអស់នោះបាន ហើយនិងយករដ្ឋាភិបាលថ្មីមកដាក់ជំនួសវិញ ។ ចំណែកបុគ្គលិកដែលសេអ៊ីអារៀបចំ - ដាក់នៅក្នុងរដ្ឋាភិបាលថ្មី អ្នកអស់នោះត្រូវបានទទួលការដឹកនាំសព្វគ្រប់ទាំង ហើយនិងពិនិត្យមើលប្រព្រឹត្តិការ [illegible]នៅកម្ពុជាជាយូរខែមកហើយ ។ បើកាលណាកងទ័ពនៃរដ្ឋាភិបាលរណបអាមេរិកកាន់ក្ដាប់ប្រព័ន្ធចាស់ចែងទីក ហើយនិងជ្រុកធំពុំបាន ហើយ - រដ្ឋាភិបាលថ្មីអាចនិងស្នើសុំជំនួយពីអាមេរិក ។ អាចសុំអ្វីពុំដែលត្រូវការបានទាំងអស់ៗ សេអ៊ីអានិងសំរេចបានគោលបំណងទាំងអស់ ហើយសេដ្ឋកិច្ចអាមេរិកនិងស្ទុះលោតជាខ្លាំង ពីព្រោះអាមេរិកត្រូវការផ្គត់សាស្ត្រាវុធជាច្រើនមកឱ្យកម្ពុជា ។

ម្យ៉ាងទៀត ថៃនិងកម្ពុជាចាប់ផ្ដើមទាក់ទងគ្នាបានល្អឡើងវិញ ហើយអាមេរិកអាចរក្សាកម្លាំងទប់ទល់និងសូវៀតបាននៅឥណ្ឌូចិន ។ ចំពោះមតិនៃប្រទេសលោកខាងលិចវិញ គ្មានចោទជាបញ្ហាអ្វីទេ ពីព្រោះគេឆាប់ផ្អើល-ខ្លាចការវាតទីនិយមរបស់សូវៀតណាស់ ។

នេះជាការនាំចេញអំពីផែនការសេអ៊ីអាដែល ឆាក់ មាក់ គីនលី និយាយ - ពន្យល់ប្រាប់មកខ្ញុំ ។ កាលណាមានរដ្ឋាភិបាលមួយថ្មីទៀងមកកាន់អំណាច កម្ពុជាអាចនិងទទួលប្រាក់កាសសំរាប់និងដាក់ទុនរកស៊ីហើយនិងបណ្ដុះលូតលាស់សេដ្ឋកិច្ចពីលោកខាងលិច ។ ដើម្បីនិងរក្សាមតិចំពោះលោកខាងលិចថាកម្ពុជានៅតែត្រូវការជំនួយ ត្រូវផ្សាយចេញនៅក្នុងការដែលតអំពីការឈ្លានពានរបស់សូវៀតមកកម្ពុជាៗដោយមាន

Extracted from ERN: 00007904-00008067

ថៃហើយនិងកម្ពុជាជាប់ជិតស្និទ្ធស្នាលយ៉ាងនេះ ប្រទេសទាំងពីរអាចរួបរួមកម្លាំងគ្នា - ដើម្បីទប់ទល់និងណាវ៉ៃហើយនិងយួន ។ ជំនួយយោធាអាមេរិកយ៉ាងសម្បើមមកកម្ពុជាអាចទប់ទល់កុំឱ្យស្ទុះរៀតពង្រីកឥទ្ធិពលខ្លួនទៅផ្នែកតទៅទៀត ។

ដល់ពេលមានសភាពការណ៍ពិតជាប្រែប្រួលហើយ ប្រទេសលោកសេរីអាចនឹងដាក់ទុនរកស៊ីហើយនិងផ្តល់ជំនួយឱ្យរដ្ឋាភិបាលនិងផ្នែកឧស្សាហកម្មធំៗផង ។ ហើយកម្ពុជានិងថៃជាប្រទេសមួយធំមួយថ្មីនៅអាស៊ីអាគ្នេយ៍ ។

ឧបសគ្គធំបំផុតដែលនាំមិនឱ្យសម្រេចផែនការនេះបាន គឺការខ្វះពត៌មានសុទ្ធស្អាតតែម្តង ។ ដោយប្រជាជនកម្ពុជារស់នៅជាសមូហភាពហើយមានការឃ្លាំមើលជាកំហិតយោធាខ្ពស់ ភ្នាក់ងារសេអ៊ីអានីមួយៗពិបាកនឹងក្លែងក្លាយខ្លួនចូលមករស់នៅ - កម្ពុជាណាស់ ។ ដូច្នេះមានតែមធ្យោបាយមួយគត់ គឺចាត់ចែងវិធានការមួយដើម្បីស៊ើបយកការក្នុងអនាគតនាពេលនេះ ។ ប៉ុន្តែការណ៍គ្មានពត៌មានជាក់លាក់ជាប្រចាំថ្ងៃទេ ផែនការសេអ៊ីអា គឺវាមិនអាចសម្រេចបានដែរ ។

រួចហើយ ឆាក់ ម៉ាក់គីនលី បញ្ជាក់ប្រាប់មកខ្ញុំ ថាខ្ញុំបានទទួលសិទ្ធិតាំងពីខែ - មិនា ឆ្នាំ ១៩៧៨ មក តាក់សេត្តិ ១ ត្រូវទទួលបានប្រាក់ខែ ៤៨០០០ ដុល្លាក្នុងមួយឆ្នាំ